# សិស្សានុសិស្សដែលរៀនចប់សាលាវិទ្យាល័យឆ្នាំ២០០៦

## ការតម្រូវដើម្បីរៀនឲ្យចប់ពីសាលាវិទ្យាល័យក្នុងក្រសួងអប់រំឡុងប៊ីច

### ការតម្រូវដើម្បីរៀនឲ្យចប់ពីវិទ្យាល័យ

សិស្សទាំងអស់ដែលរៀនចប់ពីសាលាវិទ្យាល័យក្នុងក្រសួងអប់រំឡុងប៊ីច ត្រូវតែបានធ្វើឲ្យស្របតាមការតម្រូវខាងក្រោមនេះ។

**ថ្នាក់ពេជគណិត (Algebra)**: សិស្សត្រូវបានរៀនថ្នាក់គណិតដែលមានកំរិតស្មើនិងថ្នាក់ពេជគណិត Algebra 1-2 បើសិស្សមិនបានយកថ្នាក់ពេជគណិត Algebra 1-2 កាលពីថ្នាក់ទី៧និងទី៨ទេ។

**ការប្រឡងសញ្ញាប័ត្រវិទ្យាល័យរដ្ឋកាលីហ្វ័រនីញ៉ា (CAHSEE):** ចាប់ផ្តើមជាមួយសិស្សានុសិស្សដែលត្រូវរៀនចប់សាលាវិទ្យាល័យឆ្នាំ២០០៦ សិស្សទាំងអស់ត្រូវតែបានប្រឡងឲ្យជាប់នូវការប្រឡងចេញពីវិទ្យាល័យ ទើបបានទទួលសញ្ញាប័ត្រវិទ្យាល័យ។ សិស្សណាដែលប្រឡងមិនជាប់នូវការប្រឡងនេះនឹងពុំបានទទួលសញ្ញាប័ត្រឡើយទោះបីជាគេបានធ្វើស្របតាមការតម្រូវផ្សេងៗសម្រាប់រៀនចប់ពីវិទ្យាល័យក៏ដោយ។ CAHSEE គឺជាការប្រឡងដែលមានរយៈពេលពីរថ្ងៃ ១ថ្ងៃផ្នែកភាសាសាស្ត្រនិង១ថ្ងៃទៀតផ្នែកលេខគណិត។ ការប្រឡងនេះពុំមានកំរិតម៉ោងទេ។ ចាប់ផ្តើមពីថ្នាក់ទី១០ទៅ សិស្សនិងមានឱកាស៦លើកដើម្បីប្រឡងតែសនេះឲ្យជាប់ បើសិស្សប្រឡងជាប់តែ១ផ្នែក (ភាសាសាស្ត្រឬលេខគណិត) សិស្សចាំបាច់ប្រឡងតែផ្នែកណាដែលមិនទាន់ជាប់ប៉ុណ្ណោះ។ សិស្សដែលផ្ទេរមកពីសាលាក្រៅរដ្ឋ ត្រូវតែប្រឡងCAHSEE ឲ្យជាប់ដែរទើបបានទទួលសញ្ញាប័ត្រ។

សាលាវិទ្យាល័យនិមួយៗមានផ្តល់ថ្នាក់ដើម្បីជួយរៀបបំរុងសម្រាប់ប្រឡង CAHSEE ។ សូមស៊ើបសួរអ្នកផ្តល់ឱវាទដើម្បីពត៌មានបន្ថែម។



**ការតម្រូវផ្នែកចំនួនពិន្ទុក្រេឌិតដែលត្រូវមាន:** បច្ចុប្បន្ននេះ សិស្សរាល់គ្នាត្រូវរៀនឲ្យបានពិន្ទុក្រេឌិតចំនួន២២០ក្រេឌិតឆមាសពីថ្នាក់ទី៩ដល់ទី១២ទើបនឹងបានទទួលសញ្ញាប័ត្រវិទ្យាល័យ។ ពិន្ទុក្រេឌិតនេះគឺមានរួមទាំង:

១. ថ្នាក់ដែលចាំបាច់ទាំងអស់(សិស្សទាំងអស់) ១៥០ក្រេឌិត
២. ថ្នាក់ដែលអាចរើសតាមចំណូល ៧០ក្រេឌិត

សរុប = ២២០ក្រេឌិត (220 credits)

សិស្សត្រូវបានទទួលពិន្ទុយ៉ាងហោចណាស់គឺ “D” ទើបបានទទួលក្រេឌិតសម្រាប់ការរៀនចប់ពីវិទ្យាល័យ។ ពិន្ទុ “D” ឬខ្ពស់ជាងមានតម្លៃស្មើនឹង៥ក្រេឌិតក្នុង១ឆមាស។

**ការតម្រូវផ្នែកថ្នាក់ដែលចាំបាច់ត្រូវមាន:** សិស្សរាល់គ្នាបានតម្រូវឲ្យយកថ្នាក់ទាំងអស់ខាងក្រោមនេះពីថ្នាក់ទី៩ដល់ទី១២។

***អង់គ្លេសEnglish***: ៤០ក្រេឌិតឆនូវថ្នាក់អង់គ្លេស English 1-2, 3-4, 5-6 និង English 7-8 បើសិស្សប្រឡងផ្នែកភាសាសាស្ត្រនៃតែស CAHSEE មិនជាប់ ឬថ្នាក់អង់គ្លេសសម្រាប់ថ្នាក់ទី១២ដែលមាន១០ក្រេឌិត (10-credit Senior English elective courses)

***ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រសង្គម History / Social Science***: ៣០ក្រេឌិតនូវថ្នាក់ប្រវត្តិសាស្ត្រពិភពលោកទំនើប ប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក រដ្ឋាភិបាលនិងសេដ្ឋកិច្ចសហរដ្ឋអាមេរិក (Modern World History, US History, US Government and Economics)

***គណិតវិទ្យា Mathematics***: ២០ក្រេឌិតនូវថ្នាក់គណិតវិទ្យាដែលយ៉ាងតិច១ថ្នាក់ឬ២ថ្នាក់ចូលគ្នានូវថ្នាក់ដែលស្មើនិង Algebra 1-2 ឬបើមិនបានយកថ្នាក់ Algebra 1-2 កាលពីថ្នាក់ទី៧និងទី៨ទេ។

***អប់រំកាយ Physical Education:*** ២០ក្រេឌិតក្នុងថ្នាក់ទី៩និងទី១០

***វិទ្យាសាស្ត្រ Science***: ២០ក្រេឌិត: ១០ក្រេឌិតនូវថ្នាក់វិទ្យាសាស្ត្រចំរុះ integrated science និង១០ក្រេឌិតនូវថ្នាក់ជីវវិទ្យា biological/life

***អប់រំសុខភាព Health Education***: ៥ក្រេឌិតក្នុងថ្នាក់ទី៩ឬទី១០។

***វិចិត្រសិល្បៈ ឬ ភាសាបរទេស Fine Arts or Foreign Language***: ១០ក្រេឌិតនូវថ្នាក់ភាសាបរទេសនិងមួយឆ្នាំនូវថ្នាក់សិល្បៈ (Art and Music)

*បច្ចេកទេស*: ៥ក្រេឌិតនូវថ្នាក់កុមព្យូទ័រ Computer Application I បើពុំបានយកថ្នាក់កុមព្យូទ័រ Computer នៅសាលាមធ្យមសិក្សាទេ។

***ថ្នាក់រើសតាមចំណូល Electives:*** ៧០ក្រេឌិតនូវថ្នាក់រើសតាមចំណង់